Ministry for Ethnic Communities
Te Tari Mātāwaka

# Doxing

## តើ doxing (ឬ doxxing) គឺជាអ្វី?

Doxing គឺពេលដែលនរណាម្នាក់ យកព័ត៌មានផ្ទាល់ខ្លួន ឬព័ត៌មានឯកជនរបស់អ្នក បង្ហោះ តាមអនឡាញ ដោយមិនបានស្នើសុំអ្នក ។ ព័ត៌មាននេះ គឺអាចរួមបញ្ចូលនូវ ឈ្មោះពេញ អាសយដ្ឋានផ្ទះ លេខទូរសព្ទ កន្លែងធ្វើការរបស់អ្នក ឬសូម្បីតែព័ត៌មានទំនាក់ទំនងលម្អិតរបស់គ្រួសារអ្នក ។ ជារឿយៗ អ្នកទាំងនោះ លើកទឹកចិត្តអ្នកដទៃឱ្យប្រើព័ត៌មាននេះដើម្បីបន្លាច គំរាមកំហែង យាយី ឬបំភ័យអ្នក ។

**ប្រសិនបើ doxing ត្រូវបានធ្វើឡើងសម្រាប់ ឬក្នុងនាមរដ្ឋបរទេស គេហៅថា វាគឺជាទម្រង់នៃការជ្រៀតជ្រែកពីបរទេស ។** ការចែករំលែកព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានឯកជន ជាសាធារណៈ អាចប៉ះពាល់ដល់ឯកជនភាព សន្តិសុខ និងសុវត្ថិភាពរបស់នរណាម្នាក់ ។

## អ្វីដែលត្រូវធ្វើប្រសិនបើមានគេយកព័ត៌មានរបស់អ្នកទៅបង្ហោះតាមអនឡាញ

### ត្រូវប្រាប់គ្រួសារ និងមិត្តភក្តិរបស់អ្នកឲ្យបានដឹង

ប្រសិនបើអ្នកមានអារម្មណ៍កក់ក្តៅ សូមប្រាប់ឲ្យក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នកដឹងពីអ្វីដែលបានកើតឡើង ដោយសារពួកគេអាចជាផ្ទាំងស៊ីបផងដែរ ។ ប្រាប់ឱ្យពួកគេកំណត់ទម្រង់ព័ត៌មានផ្ទាល់ខ្លួនក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម ទៅជាឯកជន ។

### ការរាយការណ៍នៅលើវេទិកា / គេហទំព័រ / អែប ដែលជាកន្លែងកើតរឿង

ប្រើមុខងារសម្រាប់រាយការណ៍ ដើម្បីរាយការណ៍នៅលើគេហទំព័រ អែប ឬវេទិកា ដែលឧប្បត្តិហេតុបានកើតឡើង ។ ឯកសារគោលការណ៍ការណែនាំអំពីប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ Netsafe មានព័ត៌មានអំពីរបៀបរាយការណ៍នេះ ។

## រាយការណ៍ទៅកាន់ Netsafe

អ្នកអាចរាយការណ៍នូវមាតិកាដែលបង្កគ្រោះថ្នាក់ ទៅដល់ Netsafe ៖
ដាក់ស្នើសំណើ – Netsafe ។
Netsafe ក៏អាចផ្តល់ឱ្យអ្នកនូវ ការគាំទ្រ ដំបូន្មាន និងជំនួយពីអ្នកជំនាញ
ចំពោះសុវត្ថិភាពអនឡាញផងដែរ ។
អ៊ីមែល help@netsafe.org.nz ឬផ្ញើសារ 'Netsafe' ទៅ 4282 ដើម្បីទទួលបានជំនួយ ។

## រាយការណ៍រឿងហេតុនេះដល់នគរបាល

ប្រសិនបើអ្នកស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ សូមទូរសព្ទទៅប៉ូលីសភ្លាមៗ តាមលេខ 111 ។

ប្រសិនបើមិនមែនជាហេតុការណ៍បន្ទាន់ទេ អ្នកអាចទាក់ទងប៉ូលីសតាមរយៈ ៖

- ការប្រើទម្រង់បែបបទ 105 តាមអនឡាញ
- ទូរសព្ទទៅលេខ 105 ពីទូរសព្ទចល័ត ឬទូរសព្ទលើតុ នៃប្រព័ន្ធណាមួយក៏បានដែរ លេខនេះគឺផ្តល់សេវាដោយឥតគិតថ្លៃ និងមានបម្រើ 24/7 ទូទាំងប្រទេស ។

នៅក្នុងទម្រង់បែបបទ 105 អ្នកត្រូវបំពេញព័ត៌មានផ្ទាល់ខ្លួនមួយចំនួន
ដើម្បីជួយប៉ូលីសក្នុងការដំណើរការរបាយការណ៍របស់អ្នក
និងតាមដានហេតុការណ៍នេះជាមួយអ្នក ។
**ក្រុមប៉ូលីសប្រើព័ត៌មាននេះសម្រាប់តែគោលបំណងដែលត្រូវបានអនុញ្ញាតប៉ុណ្ណោះ ។**

## រាយការណ៍ទៅកាន់ NZSIS

ប្រសិនបើអ្នកសង្ស័យថា មានរដ្ឋបរទេសនៅពីក្រោយការយកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក
បង្ហោះអនឡាញ ដោយមិនបានស្នើសុំអ្នក សូមរាយការណ៍រឿងហេតុនេះទៅកាន់ NZSIS
ដោយប្រើ ទម្រង់បែបបទតាមអនឡាញ ដែលមានសុវត្ថិភាពរបស់ពួកគេ ។

អ្នកមិនចាំបាច់ផ្តល់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ដូចជាឈ្មោះ លេខទូរសព្ទ
ឬព័ត៌មានទំនាក់ទំនងលម្អិតរបស់អ្នកទេ បើអ្នកមិនចង់ ។ អ្នកក៏អាចបំពេញទម្រង់បែបបទនេះ
ជាភាសារបស់អ្នកបានដែរ ។ ព័ត៌មានទាំងអស់ដែលអ្នកផ្តល់ឲ្យ**គឺជាការសម្ងាត់
និងស្ថិតក្រោមកិច្ចការពារ ។**

ប្រសិនបើអ្នកចង់និយាយជាមួយនរណាម្នាក់ធ្វើការនៅ NZSIS សូមហៅទូរសព្ទទៅកាន់លេខ
+64 4 472 6170 ឬ 0800 747 224 ។

### ព័ត៌មានដែលត្រូវចែករំលែកជាមួយ Netsafe ប៉ូលីស ឬ NZSIS នៅពេលរាយការណ៍

នៅពេលរាយការណ៍ បញ្ហាដែលបានកើតឡើង វាមានប្រយោជន៍
ក្នុងការបញ្ចូលព័ត៌មានលម្អិតឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ។ សូមថតអេក្រង់ ឬរក្សាទុកសំណៅចម្លងនៃ ៖

- ព័ត៌មានផ្ទាល់ខ្លួន ឬព័ត៌មានឯកជន ដែលត្រូវបានគេយកទៅចែករំលែក ឬបង្ហោះ
- ទម្រង់ព័ត៌មានរបស់អ្នកប្រើប្រាស់ ឬគណនីរបស់អ្នកដែលបានចែករំលែកព័ត៌មានរបស់អ្នក (ឧ. ឈ្មោះអ្នកប្រើប្រាស់)
- កាលបរិច្ឆេទ និងពេលវេលាដែលព័ត៌មានរបស់អ្នកត្រូវបានគេចែករំលែក ឬបង្ហោះ
- ឈ្មោះគេហទំព័រ ឬ អែប ដែលប្រើដើម្បីចែករំលែកព័ត៌មានរបស់អ្នក

## វិធីការពារខ្លួនអ្នកមិនឲ្យគេយកព័ត៌មានផ្ទាល់ខ្លួនទៅចែករំលែកតាមអនឡាញ

### រក្សាសុវត្ថិភាពតាមអនឡាញ

សូមអាន ការរក្សាសុវត្ថិភាពតាមអនឡាញ សម្រាប់ព័ត៌មានបន្ថែម ។

### សូមប្រយ័ត្នចំពោះការចែករំលែកព័ត៌មានតាមអនឡាញ

សូមពិនិត្យមើលការកំណត់ឯកជនភាពរបស់អ្នកនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម និងគណនីអនឡាញរបស់អ្នក ។ កំណត់ទម្រង់ព័ត៌មានរបស់អ្នកទៅជាឯកជន ដើម្បីឲ្យព័ត៌មាននេះ អាចមើលបានតែមនុស្ស ដែលអ្នកទុកចិត្តប៉ុណ្ណោះ ។

### ស្វែងរកព័ត៌មានអំពីខ្លួនឯងតាមវិបសៃត៍

ដោយរកមើលឈ្មោះ និងព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់អ្នក ដើម្បីមើលថាតើព័ត៌មានអ្វីខ្លះអំពីអ្នកដែលសាធារណៈជនអាចមើលឃើញ ។ លុបព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានឯកជនដែលមនុស្សដទៃអាចប្រើដើម្បីធ្វើបាបអ្នក ដូចជាអាសយដ្ឋានរបស់អ្នកជាដើម ។

### គ្រប់គ្រងការកំណត់ GPS និងការដាក់ស្លាកភូមិសាស្ត្រនៅលើឧបករណ៍របស់អ្នក

ទូរសព្ទវៃឆ្លាត និងកាមេរ៉ា អាចបង្កប់ទិន្នន័យប្រព័ន្ធកំណត់ទីតាំងសកល (GPS) នៅក្នុងរូបថត ដោយប្រើការកំណត់ទីតាំងរបស់អ្នក ដែលគេអាចយកទៅប្រើដើម្បីស្វែងរកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ដូចជាផ្ទះរបស់អ្នក ឬសាលារៀនរបស់កូនអ្នក ។ ការបិទមុខងារការដាក់ស្លាកភូមិសាស្ត្រ ឬការកំណត់ទីតាំងរបស់អ្នក មានភាពខុសគ្នាចំពោះឧបករណ៍នីមួយៗ សូមស្វែងរកតាមអនឡាញ ដោយប្រើឈ្មោះឧបករណ៍របស់អ្នកដើម្បីបញ្ជាក់ថា ឧបករណ៍របស់អ្នកបានបិទមុខងារទាំងនេះបានត្រឹមត្រូវ ។